# យោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន

ដំណើរការបច្ចេកទេស និងនយោបាយផែនការរៀបចំទីក្រុង ផ្តោតលើការប្រើប្រាសដី និងគូរប្លង់អំពីបរិយាកាសទីក្រុង។ ដោយថា ការរៀបចំផែនការទីក្រុងគឺជាឧបករណ៍ដ៏សំខាន់មួយ ក្នុងការអភិវឌ្ឍន៍ទីក្រុង យន្តការនៃការរៀបចំ និងការអនុវត្តនានាដែលអាចមានផលប៉ះពាល់ដោយផ្ទាល់ ទៅនឹងជីវិតរស់នៅរបស់ប្រជាពលរដ្ឋ និងចីរភាពបរិយាកាសទីក្រុង។ បច្ចុប្បន្នមានប្រជាជនពាក់កណ្តាលនៃប្រជាជននៅលើពិភពលោកកំពុងរស់នៅទីក្រុង ស្របពេលដែលអត្រាចំនួនប្រជាជនកម្ពុជានៅទីប្រជុំជនកំពុងតែកើនឡើង។ គឺចំពេលដែលព្រះរាជាណាចក្រកម្ពុជាកំពុងធ្វើសេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន។

សេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន បានដាក់ជូនទៅវិស័យសង្គមស៊ីវិលកាលពីចុងខែវិច្ឆិកាឆ្នាំ២០១១។ សិក្ខាសាលាលើកទីមួយ បើកឱ្យមានការប្រឹក្សាយោបល់ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ ហើយការផ្តួចផ្តើមដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ផ្តល់ឱកាសឱ្យសង្គមស៊ីវិលរយៈពេលមួយសប្តាហ៍ដើម្បីផ្តល់យោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជននេះ។ ដោយមានការស្នើសុំពីវិស័យសង្គមស៊ីវិលអំពីពេលវេលាកំណត់មួយ ហើយត្រូវបានពន្យាទៅដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១២វិញ។

ដូចការធ្វើគោលនយោបាយផ្សេងទៀតនាពេលថ្មីៗនេះនៅក្នុងវិស័យដី និងផែនការទីក្រុងអញ្ចឹងដែរ ក្រុមគំនិតផ្តួចផ្តើមស្តីពីទីក្រុងស្វាគមន៍រាល់ការផ្តួចផ្តើមរបស់រដ្ឋាភិបាលឱ្យមានការផ្សារភ្ជាប់ជាមួយ នឹងវិស័យសង្គមស៊ីវិលដែលពាក់ព័ន្ធលើបញ្ហានេះ និងសង្ឃឹមថា ការនេះវាជាចំណុចចាប់ផ្តើមនូវដំណើរការនៃការពិភាក្សាដ៏មានអត្ថន័យ ដែលអនុញ្ញាតឱ្យវិស័យពាក់ព័ន្ធមានការចូលរួម។

ដើម្បីអាចធ្វើឱ្យដំណើរការនេះបន្តបាន, ក្រុមគំនិតផ្តួចផ្តើមស្តីពីទីក្រុងសូមអំពាវយ៉ាងទទូចដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ពិចារណា ជួលក្រុមហ៊ុនពិគ្រោះយោបល់ ដែលមានបទពិសោធន៍លើការរៀបចំផែនការទីក្រុងឱ្យជួយកែសម្រួលអនុក្រឹត្យនេះ។ ការពីនិត្យលើងវិញនេះត្រូវធ្វើឡើងក្នុង រយៈពេលវេលាគ្រប់គ្រាន់ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នរាជរដ្ឋាភិបាល ផ្សេងទៀត ក៏ដូចជា និង ជាពិសេស តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ។

ចំណុចទាំងប្រាំពីរខាងក្រោមនេះ គូសបង្ហាញក្តីបារម្ភដ៏សំខាន់មួយចំនួន, ហើយ ក្រុមគំនិត្យផ្តួចផ្តើមពីទីក្រុង (The Urban Initiative) បានកំណត់នៅក្នុងសេចក្តីព្រាងអនុក្រឹត្យ ដែលយើងសង្ឃឹមថាការពិនិត្យ និងការពិគ្រោះយោបល់ឡើងវិញនឹងត្រូវបានលើកឡើង។ បញ្ជីនេះមិនមែនសំដៅលើកឡើងក្នុងលក្ខណៈពេញលេញទេ ដូច្នេះ វាមិនដាក់បញ្ចូលសេចក្តីអធិប្បាយលើមាត្រាដោយឡែកនីមួយៗឡើយ។

**គន្លឹះបារម្ភចម្បង:**

- អ្វីទៅជាទស្សនវិស័យ?
  - សេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន មិនបានឱ្យនិយមន័យទស្សនវិស័យច្បាស់លាស់សម្រាប់អនាគតទីក្រុង ជាពិសេសសេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជននេះ មិនបានផ្តល់មូលដ្ឋានរឹងមាំអំពី ការអភិវឌ្ឍន៍ទីក្រុង។ លើកលែងសម្បទានមួយចំនួនតូចចំពោះ "សិទ្ធិមនុស្ស" និង "ចីរភាព" (មាត្រា ២) ប៉ុន្តែការចេញ ឯកសារនេះមិនផ្តល់ជូនអ្នកនៅទីក្រុងនៃប្រទេសជាតិនូវសុបិន្តអំពី "គុជនៃទ្វីបអាស៊ី" ឬ ទីក្រុងមួយដែលនាំមុខគេនៅអាស៊ីអគ្នេយ៍លើការសម្របទៅតាមការផ្លាស់ប្តូរនៃសតវត្សរ៍ទី ២១។
  - ថ្វីបើមាត្រា ២ និង ៦ ដាក់ចេញនូវគោលបំណង និងគោលការណ៍ដ៏ខ្ពង់ខ្ពស់ក្តី ក៏មាត្រាបន្ទាប់ទាំងឡាយខកខានមិនបានប្រែក្លាយទៅជាការពិតនូវចំណុចទាំងនេះទេ ខណៈដែលបទប្បញ្ញត្តិនៃមាត្រាខ្លះហាក់បីដូចជាភាពផ្ទុយស្រឡះទៅនឹងគោលបំណង និងគោលការណ៍ទាំងនោះ។

- លទ្ធភាពអនុវត្ត/លទ្ធភាពប្រតិបត្តិ
  - មាត្រាខ្លះចែងពីលក្ខខណ្ឌលម្អិតច្រើនពេក ក៏ប៉ុន្តែវាមិនមានភាពច្បាស់លាស់ ថាតើមាត្រាទាំងនេះអាចប្រព្រឹត្តិទៅបានដោយគ្មានការបង្កើតនាយកដ្ឋានអធិការកិច្ចដ៏ធំ និងមានការចំណាយច្រើន។ ឧទាហរណ៍ ក្នុងមាត្រា ២២ ចែងពីសមាមាត្រដែលមានលក្ខណៈដូចជាមិនសមហេតុផលសម្រាប់ផ្ទៃដីអាចសាងសង់បាន ប្រៀបធៀបទៅនឹងផ្ទៃដីបន្ថែមលើការកំណត់ចំនួនដើមឈើដែលចាំបាច់ត្រូវដាំក្នុងផ្ទៃដីទំហំ ១៥០ ម៉ែត្រការ៉េ។ ខណៈដែល មាត្រា ២៨ ដែលតម្រូវឱ្យការគណនាច្រើនអំពីទំហំ។
  - មាត្រាខ្លះហាក់ដូចជាមិនពាក់ព័ន្ធទៅនឹងអនុក្រិត្យស្តីពីផែនការនៃការរៀបចំទីក្រុង។ ឧទាហរណ៍ មាត្រា ៣១ ទាក់ទិននឹងលំហររវាងអាគារ និង ព្រំដីស្របច្បាប់ សមស្ថិតនៅក្នុងឯកសារមួយស្តីពីគោលការណ៍ណែនាំអំពីសំណង់។
  - ជាចុងក្រោយ មាត្រាខ្លះហាក់បីដូចជាចម្លែក និង/ឬ ខ្វះភាពទន់ភ្លន់ ឧទាហរណ៍ មាត្រា ៤៣ ស្តីពីសាលារៀន មានលក្ខណៈចង្អៀតពេក និងមិនបានផ្តល់ឱ្យមានបរិយាកាសទីក្រុងផ្សេងគ្នា។
- សមត្ថភាពបច្ចុប្បន្ន
  - គេហាក់បីដូចជាឃើញមានការទទួលស្គាល់ថាមានកង្វះសមត្ថភាពមនុស្ស ជាមូលដ្ឋានមួយ មិនត្រឹមតែនៅកម្រិតមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទៀតផង។ ផ្នែកស្នូលមួយនៃអនុក្រឹត្យ គប្បីចែងពីការអប់រំ និងអាហារូបករណ៍សម្រាប់ជំនាន់ថ្មីមួយនៃអ្នកធ្វើផែនការកម្ពុជា ហើយ ទន្ទឹមនឹងនេះ អភិវឌ្ឍវិធីមួយដើម្បីជួយមន្ត្រីមូលដ្ឋានឱ្យមើលយល់ផែនទីនិងឯកសារបច្ចេកទេស។

- វិធីសាស្ត្រថ្មីស្តីពីផែនការរៀបចំទីក្រុង
  - សេចក្តីព្រាងអនុក្រឹត្យ ហាក់បីដូចជាមិនគិតគូរដល់ថាតើមណ្ឌលទីក្រុងកម្ពុជានៅពេលនេះស្ថិតនៅទីណា - ការដាក់និយតកម្មផែនការលើប្រព័ន្ធមួយដែលកំពុងជួលជុលបានដួលរលំ ទំនងជានឹងបរាជ័យ។ ក្នុងកម្រិតពិភពលោក អភិក្រមរៀបចំផែនការទីក្រុងជាប្រពៃណីបាន និងកំពុងធ្វើឱ្យមានការខកចិត្តចំពោះទីក្រុងអស់ពេលពីរបីឆ្នាំហើយ ជាពិសេសទីក្រុងទាំងឡាយដែលមាននិគមក្រីក្រទីប្រជុំជនច្រើន។ ការកំណត់តំបន់ និងការធ្វើផែនការ និងការដាក់កំហិតលើកម្ពស់ ជារឿយៗគឺគ្មានន័យទេ នៅក្នុងបរិបទនៃនគរូបនីយកម្មដ៏លឿននាបច្ចុប្បន្ននេះ។ នៅរាជធានីភ្នំពេញ ឧបករណ៍ បែបនេះ អាចសមស្របសម្រាប់តែតំបន់ជាប់លាប់មួយចំនួនតូចដែលប្លង់ដើមរៀបចំដោយបារាំងនៅមានអាត្ថិភាព ប៉ុន្តែ វាគឺមិនសមស្របទាល់តែសោះសម្រាប់ចាត់ចែងការលូតលាស់នៃទីក្រុងជារួម។ អភិក្រមស្រាលជាង និងទន់ភ្លន់ជាងមួយចាំបាច់ត្រូវអនុម័ត។

- ច្បាប់ និងយន្តការនានាដែលមានលក្ខណៈត្រួតលើគ្នា
  - បទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ហាក់បីដូចជាជាន់/ត្រួតលើច្បាប់មានស្រាប់ គឺផ្ទុយគ្នា និងត្រួតគ្នាជាមួយនឹងច្បាប់ អនុក្រឹត្យ និង គោលនយោបាយជាធរមានទាក់ទិននឹងការអភិវឌ្ឍដី សំណង់ និង ការប្រើប្រាស់ដី។ ឧទាហរណ៍ សូមមើលមាត្រា ៧
  - យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក៏ត្រួតគ្នាជាមួយនឹងយន្តការ និងដំណើរការមានស្រាប់ផងដែរ។ ឧទាហរណ៍ សូមមើលមាត្រា ១៤។

- ការសម្របសម្រួលរបស់ក្រសួងនានា
  - ផែនការរៀបចំទីក្រុងមានការពាក់ព័ន្ធជាមួយនឹងគ្រប់ក្រសួងទាំងអស់ មិនមែនត្រឹមតែក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មួយនោះទេ។ ចំណុចនេះគួរតែបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ទោះបីឯកសារនោះមិនបានបាកស្រាយយ៉ាងពេញលេញអំពីរបៀបសម្របសម្រួលដែលនឹងត្រូវអនុវត្តក៏ដោយ។
  - នៅពេលសេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជននេះកើតឡើងវាហាក់បីដូចជាក្រសួងជាច្រើន និងជាពិសេសបុគ្គលិកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនបានដឹងអំពីការពង្រាងនេះ។ ការនេះបង្កើតឡើងនូវសំណួរសំខាន់ៗជាច្រើនអំពីការពិគ្រោះយោបល់នៅក្នុងថ្នាក់ដឹងនាំក្រសួងរបស់រដ្ឋាភិបាល។

- លក្ខណៈពីលើចុះក្រោម / ការពិគ្រោះយោបល់មានកម្រិត
  - ទោះបីជាមានការអះអាងអំពីវិសហមជ្ឈការនិងវិមជ្ឈការ (មាត្រា ៦) ក្តី ក៏សេចក្តីព្រាងអនុក្រឹត្យនៅតែគឺជាយន្តការរៀបចំផែនការបែបមជ្ឈការពីលើចុះក្រោមមួយដដែល។
  - ថ្វីបើការចូលរួម និងការពិគ្រោះយោបល់សហគមន៍ និងសង្គមស៊ីវិលត្រូវបានលើកឡើងនៅក្នុងឯកសារនេះក្តី ក៏ពុំមានការផ្តល់ចំណុចលម្អិតអំពីរបៀបធានាឱ្យបានថាការពិគ្រោះយោបល់បែបនេះ

មានអត្ថន័យ និង មិនមែនធ្វើឡើងតែនៅពេលដែលផែនការត្រូវបានបញ្ចប់នោះទេ ប៉ុន្តែ ថែមទាំងនៅក្នុងអំឡុងពេលរៀបចំផងដែរ។
 - ពេលវេលាសម្រាប់ការផ្តល់យោបល់លើផែនការផ្សេងៗ គឺមិនគ្រប់គ្រាន់។
 - ពុំមានការទទួលស្គាល់លើគម្រូរៀបចំផែនការបែបពីក្រោមឡើងលើ ដូចជា ការរៀបចំផែនការសហគមន៍ជាដើម។

- ការបកស្រាយខុស / ការប្រើបំពាន / អំពោះពុករលួយ
  - មាត្រាខ្លះហាក់បីដូចជាមានការបកស្រាយខុសតាមតែការយល់ឃើញរបស់ខ្លួន។ ឧទាហរណ៍ មាត្រា ១៨, ២២, ៣២, ៤៩, ៦៩ អាចត្រូវបានប្រើដើម្បីបណ្តេញចេញប្រជាជន និង/ឬ ធ្វើអស្សាមិករណ៍ដី។
  - មាត្រាផ្សេងទៀត ដែលមិនចាំបាច់ ហាក់បីដូចជាទុកឱ្យមានភាពចន្លោះប្រហោង សម្រាប់អំពើពុករលួយ។ ឧទាហរណ៍ មាត្រា ២៩ ទាក់ទិន នឹងសំណើសុំប្រើដីហួសពីកម្រិតអតិបរមានៃសន្ទស្សន៍ប្រើប្រាស់ដី។

ក្រុមអ្នកផ្តួចផ្តើមស្តីពីទីក្រុង គឺជាកម្រោងឯករាជ្យមួយស្ថិននៅក្រោមអង្គការសមាគមធាងត្នោត។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា នោរ៉ា លឹមស្រ្តម, ប្រធានគម្រោង nora@the-ui.org